# បទឧទ្ទេសនាម

## របស់

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភា ដើម្បីពិភាក្សា និង អនុម័ត សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

*រដ្ឋសភា, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០*

ខ្ញុំបាទសូមគោរព ៖

- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;
- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អនុប្រធានទី ១ នៃរដ្ឋសភា;
- លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី ២ នៃរដ្ឋសភា;
- សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា, នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំបាទសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម ព្រមទាំងគណៈកម្មការពាក់ព័ន្ធទាំងអស់នៃរដ្ឋសភា, និង អង្គរដ្ឋសភាទាំងមូល, ដែលបានចាត់ការយ៉ាងរួសរាន់ ដើម្បីពិនិត្យ និង អនុម័តដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១** ចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃនេះ ។ អាស្រ័យដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីថ្លែងហេតុពិស្តារមួយគោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និង អង្គសភារួចហើយ, ហើយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** ក្នុងនាមគណៈកម្មការទី ២ នៃរដ្ឋសភា ក៏បានរាយការណ៍បន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញនេះ រួមទាំងអំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម, និង រចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះផង; ដូច្នេះ នៅពេលនេះ ខ្ញុំបាទសូមអនុញ្ញាត

ធ្វើបទឧទ្ទេសនាមដោយសង្ខេបខ្លះដើម្បីចំណេញពេល ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទគោរពសុំការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬសង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** បានរាយការណ៍ជូនអង្គរដ្ឋសភាមុននេះ ។

## I. អំពីបរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២១

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ត្រូវបានរៀបចំឡើងនៅក្នុងខណៈដែលប្រទេសជាតិកំពុងស្ថិតនៅក្នុងស្ថានភាពលំបាកនៃវិបត្តិជំងឺកូវីដ-១៩ ហើយជំនន់ទឹកភ្លៀងនាពេលថ្មីៗកន្លងមកនេះ ក៏បានបង្កើនសម្ពាធនៃតម្រូវការចំណាយថវិកានៅឆ្នាំ ២០២១ ខាងមុខ សម្រាប់គោលដៅនៃការស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផលិតកម្មកសិកម្ម ដែលបាន និង កំពុងទទួលរងការខូចខាត ។

ជាក់ស្តែង, ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ដ៏កាចសាហាវ បាន និង កំពុងបន្តនាំមកនូវផលប៉ះពាល់អវិជ្ជមាន, បញ្ហាប្រឈម និង ហានិភ័យជាច្រើន ដែលមិនធ្លាប់មានពីមុនមក ចំពោះតំបន់ និង ពិភពលោកទាំងមូល ដោយគ្មានការលើកលែងចំពោះប្រទេសណាមួយឡើយ, ពិសេសគឺបានធ្វើឱ្យមនុស្សរាប់លាននាក់បាត់បង់ការងារ, ធ្លាក់ចុះនូវប្រាក់ចំណូល, ហើយប្រជាជនមួយចំនួនធំនៅលើពិភពលោក ត្រូវធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ ។ កម្ពុជាក៏មិនអាចគេចរួចពីវិបាកអាក្រក់ទាំងនេះដែរ ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ, តែថែមទាំងអាចទាញបង្អន់ល្បឿននៃកិច្ចដំណើរការអភិវឌ្ឍន៍ឈានឡើងរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេលនៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ជាប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ ផងដែរ ។ យ៉ាងណាក៏ដោយ, មកដល់ពេលនេះ, ទោះបីកម្ពុជាជាប្រទេសតូច ហើយធនធានក៏នៅមានកម្រិតក្តី, ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ, ឈ្លាសវៃ និង ម៉ឺងម៉ាត់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ, រាជរដ្ឋាភិបាលមានសមត្ថភាព និង លទ្ធភាពអាចគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ បានល្អប្រសើរ ដោយផ្អែកលើមូលដ្ឋានគ្រឹះរឹងមាំនៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ដែលយើងខិតខំកសាងបាននៅក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមក, ពិសេស ក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយ, ព្រមជាមួយនឹងការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ផ្លូវការ, វិស័យឯកជន និង អង្គការសង្គមស៊ីវិលផងដែរ ។

មួយវិញទៀត, ថវិកាឆ្នាំ ២០២១ ក៏ជាថវិកានៃឆ្នាំពាក់កណ្តាលអាណត្តិ ដើម្បីបម្រើឱ្យសំណូមពរនៃការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ដែលត្រូវបានកំណត់នៅក្នុង **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា និង យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤,** នៅលើមាគ៌ានៃការកែទម្រង់ស៊ីជម្រៅ និង ការជំរុញការអភិវឌ្ឍ ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលជាច្រើនដែលសម្រេចបានកន្លងមក, ទាំងខាងនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម, និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ពិសេសគឺ សន្តិភាព និង ស្ថិរភាព-នយោបាយដ៏រឹងមាំ ជាប់មិនដាច់ ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត និង មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍជាតិ និង ភាពសុខក្សេមក្សាន្តរបស់ប្រជាជន ។

លើសពីនេះ, ជាមួយនឹងកិច្ចប្រឹងប្រែងតស៊ូជម្នះនឹងវិបត្តិនៃជំងឺកូវីដ-១៩, សំដៅកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះមកលើសុខភាព ជីវភាពរស់នៅរបស់ប្រជាជន និង សង្គម-សេដ្ឋកិច្ចទាំងមូល, រាជរដ្ឋាភិបាលក៏បាន និង កំពុងគិតគូរដើម្បីចេញដាក់ចេញនូវ **“ផែនការស្តារសេដ្ឋកិច្ចឡើងវិញ”** សម្រាប់ឆ្នាំ ២០២១-២០២៣, ដែលជាការត្រៀមខ្លួនសម្រាប់ដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ (Post Covid-19), ដើម្បីឈានទៅបង្កើតបាននូវភាពធន់ (Resiliency) របស់កម្ពុជា ទៅនឹងវិបត្តិសម្រាប់រយៈពេលវែងខាងមុខ, រួមបញ្ចូលនូវវិបត្តិសេដ្ឋកិច្ច, ការប្រែប្រួលអាកាសធាតុ និង ការរាតត្បាតនៃជំងឺឆ្លងនានា ផងដែរ ។ ផែនការស្តារនេះ ត្រូវបានគិតគូរដោយផ្តោតលើសសរទ្រូង ៣ ជាសំខាន់ រួមមាន ៖

(១)-ការដាក់ចេញនូវគោលនយោបាយចម្រុះ ទាំងខាងផ្នែកគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុ ដើម្បីធ្វើឱ្យសេដ្ឋកិច្ចត្រឡប់មកស្ថិតនៅលើគន្លងនៃកំណើនឡើងវិញ ក្នុងគោលដៅ, ម្ខាង, ដើម្បីធានាភាពរស់រាន (survive) និង, ម្ខាងទៀត, ដើម្បីធ្វើឱ្យរស់រវើកឡើងវិញ (Revive) ទាំងខាងផ្នែកជីវភាពរស់នៅរបស់ប្រជាជន, ក៏ដូចជាផ្នែកអាជីវកម្ម និង ធុរៈកិច្ច និង សង្គមទាំងមូល ព្រមជាមួយនឹងការតម្រង់ធនធានទៅលើវិស័យសុខាភិបាល, វិស័យកសិកម្ម, វិស័យទេសចរណ៍ និង សហគ្រាសធុនតូច និង មធ្យម;

(២)-ការដាក់ចេញវិធានការកែទម្រង់សំខាន់ៗ ពិសេស ផ្នែករចនាសម្ព័ន្ធដែលមានលក្ខណៈបន្ទាន់, ដោយផ្អែកលើមេរៀន និង បទពិសោធន៍ដែលកើតចេញពីវិបត្តិ, ដើម្បីប្រែក្លាយវិបត្តិនេះ ទៅជាកាលានុវត្តភាព សម្រាប់បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក៏ដូចជា ដើម្បីកសាងនូវមូលដ្ឋានគ្រឹះសម្រាប់ឈានទៅសម្រេចភាពធន់ (Resiliency) របស់កម្ពុជា;

(៣)-ការបង្កើនការវិនិយោគសាធារណៈលើវិស័យគន្លឹះៗ ដែលនឹងធានាឱ្យមានភាពធន់ (Resiliency) ប្រកបដោយបរិយាប័ន្ន និង ចីរភាព, រួមទាំងចីរភាពផ្នែកបរិស្ថាន និង ភាពឆ្លើយ-

តបទៅនឹងការប្រែប្រួលអាកាសធាតុផង, សម្រាប់រយៈពេលវែង, តាមរយៈការផ្តល់អាទិភាពទៅលើ ៖ ការពង្រឹងរដ្ឋបាលសាធារណៈ, ការពង្រឹងការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធគន្លឹះៗ ទាំងរូបវន្ត និង ឌីជីថល, ការពង្រឹងប្រព័ន្ធគាំពារសង្គម, ការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង វិស័យហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងប្រព័ន្ធសុខាភិបាល ជាដើម ។

អាស្រ័យហេតុនេះ, រាជរដ្ឋាភិបាលបានប្រសិទ្ធនាម ថវិកាឆ្នាំ ២០២១ ថាជា "**ថវិកាប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និង ជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលស្រាកស្រាន្តពីវិបត្តិជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព, ស្ថិរភាពសង្គម និង ចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន**" ។

## II. អំពីអភិក្រម និង គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០២១

នៅក្នុងបរិការណ៍រួមដូចបានគូសបញ្ជាក់ខាងលើ, ថវិកាឆ្នាំ ២០២១ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **អភិក្រមគ្រឹះ** ជាយុទ្ធសាស្ត្រសំខាន់ចំនួន ៥ រួមមាន៖

(១)-ទប់ទល់ការរាតត្បាត និង កាត់បន្ថយផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ព្រមទាំងរក្សាលំនឹងជីវភាពប្រជាជន និង ស្ថិរភាពសង្គម;

(២)-ខិតខំសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៣,៥% ដើម្បីបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជន, ព្រមទាំងផ្តល់លទ្ធភាពឱ្យប្រជាជនអាចទទួលបានប្រាក់ចំណូលខ្ពស់ជាលំដាប់ឡើងវិញ និង ជំរុញបង្កើនចំណូលថវិកាជាតិ;

(៣)-ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការគ្រប់គ្រងបាននូវអតិផរណា និង ការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ;

(៤)-បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន តាមការសន្យា, ក៏ដូចជាពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និង សមត្ថភាពនៃវិស័យសាធារណៈ ដើម្បីពង្រីកវិសាលភាព និង ពង្រឹងគុណភាពនៃសេវាសាធារណៈ និង សេវាយុត្តិធម៌; និង

(៥)-ជំរុញការអនុវត្តការកែទម្រង់រចនាសម្ព័ន្ធ, ក្នុងលក្ខណៈបន្ទាន់, នៅតាមការដ្ឋានចាំបាច់នានា សំដៅស្តារសេដ្ឋកិច្ច, ពង្រឹងភាពប្រកួតប្រជែង និង ធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីធានាចីរភាពនៃកំណើន ។

ផ្អែកលើអភិក្រមគ្រឹះជាយុទ្ធសាស្ត្រខាងលើ, ថវិកាឆ្នាំ ២០២១ ក៏ត្រូវបានរៀបចំឡើងដោយឈរលើ **គោលការណ៍បច្ចេកទេសសំខាន់ៗ** ចំនួន ៧ ទៀត រួមមាន៖ (១)-**ការធានាចីរភាព និង សមិទ្ធកម្មនៃចំណូល**, (២)-**ការកំណត់លំដាប់អាទិភាព**, (៣)-**ការយកចិត្តទុកដាក់លើមនុស្ស**, (៤)-**ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព**, (៥)-**ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត**, (៦)-**ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និង ការវិភាជថវិកា**, និង (៧)-**ការរក្សាតុល្យភាព និង ចីរភាពថវិកា** ។

## III. អំពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច

នៅក្នុងផ្នែកនេះ, អាស្រ័យដោយអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ បានគូសរំលេចរួចហើយអំពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២១ ក៏ដូចជាអំពីបញ្ហាប្រឈម និង ហានិភ័យ, ទាំងផ្នែកក្រៅប្រទេស, ទាំងផ្នែកក្នុងប្រទេស, ព្រមទាំងអំពីវិធានការគោលនយោបាយមុតស្រួចមួយចំនួន ដែលត្រូវបានដាក់ចេញ ដើម្បីធានារក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ដើម្បីសម្រេចឱ្យបានកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និង បរិយាប័ន្ន, ដូចនេះ, ខ្ញុំបាទសូមជម្រាបជូនជាសង្ខេបថា តាមការវាយតម្លៃពាក់កណ្តាលឆ្នាំកន្លងមក, សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០២០ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមានក្នុងអត្រា -១,៩%, ខណៈដែលការវាយតម្លៃឡើងវិញរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗនាពេលថ្មីៗនេះ បានខិតមកកៀកនឹងកម្រិតអវិជ្ជមានជាង -២% ។ ដោយឡែក, សម្រាប់ឆ្នាំ ២០២១ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា នឹងសម្រេចបានកំណើនក្នុងរង្វង់ **៣,៥%** ហើយ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថា នឹងកើនឡើងដល់ **១ ៧៧១** ដុល្លារអាមេរិក, លើសឆ្នាំ ២០២០ ដែលមានទំហំតែ **១ ៦៨៣** ដុល្លារអាមេរិក ប៉ុណ្ណោះ ។ ប៉ុន្តែ, សេដ្ឋកិច្ចកម្ពុជាអាចជួបប្រទះនឹងបញ្ហាប្រឈម និង ហានិភ័យកាន់តែខ្ពស់, ទាំងទិដ្ឋភាពខាងក្នុង និង ខាងក្រៅ, ដែលអាចនឹងប៉ះពាល់ដល់ចីរភាពនៃកំណើន និង និរន្តរភាពនៃការអភិវឌ្ឍប្រទេស ។ ដូចនេះ, ដើម្បីត្រៀមខ្លួនដោះស្រាយហានិភ័យចម្បងៗជាយថាហេតុ, រាជរដ្ឋាភិបាលបានគិតគូរជាយុទ្ធសាស្ត្រ ដោយឈរលើស្មារតីប្រុងប្រយ័ត្នខ្ពស់ និង ដាក់ឱ្យអនុវត្តនូវវិធានការអន្តរាគមន៍សមស្រប និង ទាន់ពេល តាមរយៈបន្សំនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, គោលនយោបាយរូបិយវត្ថុ, និង គោលនយោបាយកែទម្រង់រចនាសម្ព័ន្ធ, ក្នុងគោលបំណង **រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និង ជំរុញកំណើនឡើងវិញ** ដូចមានចែងលម្អិតនៅក្នុងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ ដោយផ្តោតលើ ៖ (១)-ការបន្តប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩; (២)-ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម; (៣)-ការបន្តរក្សាលំនឹងជីវភាពប្រជាជន; (៤)-ការបន្តបង្កើនភាពប្រកួតប្រជែង; (៥)-ការជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច; និង (៦)-ការបន្តកែទម្រង់រចនាសម្ព័ន្ធ ។

## IV. អំពីក្របខណ្ឌថវិកាឆ្នាំ ២០២១

ក្នុងក្របខណ្ឌនៃគោលនយោបាយវិត្ថារកម្មថវិកា (Stimulus Budget) ថវិកាឆ្នាំ ២០២១ ត្រូវបានកំណត់ដូចតទៅ ៖

១-ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ចំណូលក្នុងប្រទេសថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **២១,៤ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៥,៣ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **១៨,១៨%** នៃ ផសស, **ថយចុះ ១៨,៦%** ធៀបនឹងច្បាប់ឆ្នាំ ២០២០ ។ ក្របខណ្ឌថវិកាឆ្នាំ ២០២១ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង **១៨%** នៃ ផសស ដែល **ថយចុះចំនួន ៥,៦៣ ពិន្ទុភាគរយ នៃ ផសស** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ពោលគឺនឹងសម្រេចបានទាបជាង **គោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ** ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម **០,៣ ពិន្ទុភាគរយ** នៃ ផសស ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣, ដោយសារកត្តាសត្យានុម័តនៃវិបត្តិជំងឺកូវីដ-១៩ ។

២-ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **៣២,០ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៧,៩ ប៊ីលានដុល្លារអាមេរិក**, ស្មើនឹង **២៧,១៤%** នៃ ផសស, **ថយចុះ ៤,០%** ធៀបនឹងច្បាប់ឆ្នាំ ២០២០; ក្នុងនោះ ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងចំនួន **១៨,៨ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៤,៦ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា ១៥,៩០% នៃ ផសស, **ថយចុះ ៥,៤%** ធៀបនឹងច្បាប់ឆ្នាំ ២០២០; ដោយឡែកចំណាយមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន **១៣,២ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៣,២ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា ១១,២៤% នៃ ផសស, **ថយចុះត្រឹមតែ ១,៩% ធៀបនឹងច្បាប់ឆ្នាំ ២០២០** ។

៣- តុល្យភាពរួមនៃថវិកាឆ្នាំ ២០២១

នៅក្នុងក្របខណ្ឌថវិការដ្ឋ ឬ ថវិកាជាតិខាងលើ, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ **២,១០%** នៃ ផសស នៅឆ្នាំ ២០២១ ធៀបនឹងច្បាប់ឆ្នាំ ២០២០ ដែលមានចំនួន **៥,៧២%** នៃ ផសស ។ ជាលទ្ធផល, ឱនភាពថវិកាជាតិសរុបនឹងមានទំហំស្មើនឹង **-៨,៩៦%** នៃ ផសស គឺកើនឡើងពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០២០ ដែលស្មើនឹង **-៦,៣៣%** នៃ ផសស ។ ឱនភាពនេះ ត្រូវបានបំពេញតុល្យភាពដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ **៤,៦៣%** នៃ ផសស, មូលនិធិទ្រទ្រង់ថវិកាប្រមាណជា **០,៧៣%** នៃ ផសស និង ប្រាក់បញ្ញើរាជរដ្ឋាភិបាលក្នុងទំហំ **៣,៦០%** នៃ ផសស ស្មើនឹង **៤ ២៤១ ប៊ីលានរៀល ឬ សមមូលនឹង ១ ០៤៣**

**លានដុល្លារអាមេរិក** សម្រាប់អនុវត្តគោលនយោបាយ និង វិធានការរក្សាលំនឹងទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ព្រមទាំងសម្រាប់ការស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ។

## V. អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២១ មានគោលដៅប្រមូលចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យមានទំហំស្មើនឹង **១៩,៩ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៤,៩ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **១៦,៩០%** នៃ ផសស, គឺមានការ**ថយចុះ ១៧,៣%** ធៀបនឹងច្បាប់ឆ្នាំ ២០២០ ។ ក្នុងក្របខណ្ឌនេះ, ខ្លឹមសារពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ បានរៀបរាប់រួចហើយអំពីគោលដៅសម្រាប់ចំណូលចរន្ត, ទាំងគោលដៅចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ, ព្រមទាំងអំពីគោលដៅចំណូលមូលធន, ទាំងចំណូលមូលធនក្នុងប្រទេស និង ចំណូលមូលធនក្រៅប្រទេស ។ ដូច្នេះ, ដើម្បីបានចំណេញពេលវេលាខ្លះ, ខ្ញុំបាទសូមគ្រាន់តែស្នើសុំគូសរំលេចបន្ថែមថា ដើម្បីរួមចំណែកសម្រេចគោលដៅចំណូលសារពើពន្ធដែលត្រូវបានដាក់ចេញមកនេះ, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, និង អគ្គនាយកដ្ឋានពន្ធដារ, ដែលជាអង្គភាពប្រមូលចំណូលធំពីរ ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុផ្ទាល់, ត្រូវខិតខំសម្រេចឱ្យបានតាមគោលដៅ ដូចខាងក្រោម ៖

- ចំណូលគយ និង រដ្ឋាករ ត្រូវបានគ្រោងប្រមាណ **៩,៥ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **២,៣ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **៨,០៥%** នៃ ផសស, គឺ**ថយចុះ ១៨,៥%** ធៀបនឹងច្បាប់ឆ្នាំ ២០២០;
- ចំណូលពន្ធដារ ត្រូវបានគ្រោង **៨,០ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **២,០ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **៦,៨០%** នៃ ផសស, គឺមានការ**ថយចុះ ១៥,០%** ធៀបនឹងច្បាប់ឆ្នាំ ២០២០ ក្នុងពេលដែលនៅឆ្នាំ ២០២១ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬ បង្កើនអត្រាពន្ធនោះទេ ក៏ប៉ុន្តែ អាចនឹងបន្តពិចារណាសម្រួលដល់ការអនុគ្រោះពន្ធខ្លះថែមទៀតផង ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និង សកម្មភាពធុរកិច្ច នៅក្នុងប្រទេសឱ្យកាន់តែច្រើន ។

### ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

#### ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

**ក-១- អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ**

ថវិកាថ្នាក់ជាតិឆ្នាំ ២០២១ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឱ្យស្ថិតក្នុងកម្រិត ប្រមាណ **១៧,៤ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៤,៣ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **១៤,៧៩%** នៃ ផសស, គឺ**ថយចុះ ៣,៣%** ធៀបនឹងច្បាប់ឆ្នាំ ២០២០ ដែលក្នុងនោះ ៖

ក.១.១-ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងប្រមាណ ៨,៦ ទ្រីលានរៀល, មានសមាមាត្រស្មើនឹង ៤៩,១% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា ៧,២៦% នៃ ផសស, មានកំណើន ០,៣% ធៀបនឹងច្បាប់ឆ្នាំ ២០២០ ។ ចំណាយបន្ទុកបុគ្គលិកនេះ ត្រូវបានគ្រោងដោយរក្សាកម្រិតប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និង កម្លាំងប្រដាប់អាវុធ ព្រមទាំងប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យាឆ្នាំ ២០២១ **ស្មើនឹងកម្រិតឆ្នាំ ២០២០** ដើម្បីសន្សំថវិកាសម្រាប់ទប់ទល់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបានបង្កនូវផលប៉ះពាល់ដល់សេដ្ឋកិច្ច សុខភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស កម្មករ-និយោជិតនៃឧស្សាហកម្មកាត់ដេរ និង វាយនភណ្ឌ, កម្មករក្រៅប្រព័ន្ធ, ក៏ដូចជា ប្រជាជនក្រីក្រ និង ជនងាយរងគ្រោះ ។ ក៏ប៉ុន្តែ សម្រាប់មន្ត្រីរាជការ, រាជរដ្ឋាភិបាលបន្តធានាបាននូវការបើកផ្តល់បៀវត្សទាន់ពេលវេលា គឺ **២ ដង ក្នុង ១ ខែ** តាមរយៈប្រព័ន្ធធនាគារ ។ ចំពោះផ្នែកសោធននិវត្តន៍, រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន **៣០ ប៊ីលានរៀល** សម្រាប់ការកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជនរវាងអ្នកចូលនិវត្តន៍ចាស់ និង អ្នកចូលនិវត្តន៍ថ្មី ព្រមទាំងបានគ្រោងដោយឡែកផ្សេងទៀតនូវថវិកាសម្រាប់ផ្តល់លទ្ធភាពដល់ក្រសួង-ស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាព និង ជំនាញ-ខ្ពស់ចូលបម្រើការងាររដ្ឋ, ថវិកាសម្រាប់មូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន និង ថវិកាសម្រាប់ទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ។

ក.១.២-ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវបានគ្រោងប្រមាណ ៨,៩ ទ្រីលានរៀល, មានការថយចុះ ៦,៥% ធៀបនឹងច្បាប់ឆ្នាំ ២០២០, ត្រូវជា ៧,៥៣% នៃ ផសស, និង មានសមាមាត្រស្មើនឹង ៥០,៩% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ។ គម្រោងចំណាយនេះត្រូវបានរៀបចំឡើង, ម៉្យាង, នៅក្នុងក្របខណ្ឌនៃការធ្លាក់ចុះនៃចំណូល ដោយសារឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩, និង ម្យ៉ាងទៀត, ក្នុងគោលដៅសន្សំធនធានសម្រាប់បន្តអន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និង បន្តជំរុញរបៀបវារៈកែទម្រង់មុតស្រួចរបស់រាជរដ្ឋាភិបាល ។ ចំពោះការវិភាជវិញ, វិស័យសង្គមកិច្ចនៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី ១ ដោយក្នុងនោះអាទិភាពចំណាយត្រូវបានផ្តោតទៅលើ ៖ ការបន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ (ចំនួន ១២០ ប៊ីលានរៀល), ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និង ការពង្រីកការទទួលបានសេវាសុខាភិបាល ជាពិសេស សម្រាប់ប្រជាជនក្រីក្រ, ក្រុមជនងាយរងគ្រោះ, ស្ត្រី និង កុមារ តាមរយៈការបន្តគាំទ្រដល់កម្មវិធីមូលនិធិសមធម៌ និង ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល; ការបន្តបង្កើនកញ្ចប់ថវិកាប្រតិបត្តិការជូនដល់មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព; ការបន្តគាំទ្រដល់ការពង្រីកការទទួលបានសេវាអប់រំ និង ការលើកកម្ពស់

គុណភាពអប់រំ; ការអភិវឌ្ឍជំនាញក្នុងវិស័យឧស្សាហកម្ម ដោយផ្ដល់អាទិភាពពិសេសលើការបណ្ដុះបណ្ដាលជំនាញវិញ្ញាបនប័ត្រកម្រិតទី ១ (C1), ម្យ៉ាង, ដើម្បីជួយដល់កម្មករ-និយោជិត ដែលបាត់បង់ការងារដោយសារផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និង, ម្យ៉ាងទៀត, ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ព្រមជាមួយនឹងការបន្តគាំទ្រដល់គោលនយោបាយគាំពារសង្គមមានជាអាទិ៍ ៖

(១)-*របបថែទាំសុខភាពសម្រាប់កម្មករ* ៖ បានត្រៀមថវិកាចំនួន **១០ ប៊ីលានរៀល** សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្ដល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទទួលបានរបបថែទាំសុខភាព ដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ ។

(២)-*របបឧបត្ថម្ភមាតុភាពសម្រាប់កម្មករ* ៖ បានត្រៀមថវិកាចំនួន **៤០ ប៊ីលានរៀល** សម្រាប់បើកផ្ដល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយពេលសម្រាលកូនរួច តាមការកំណត់របស់រាជរដ្ឋាភិបាល ។

(៣)-*ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា* ៖ បានគ្រោងថវិកាចំនួន **៤០ ប៊ីលានរៀល** សម្រាប់បង្កើន «**មូលនិធិគន្ធបុប្ផាកម្ពុជា**», ព្រមគ្នាជាមួយនឹងការបន្តផ្ដល់ថវិកាចំនួន **៤១ ៣៣៦ លានរៀល** ជូនទៅមន្ទីរពេទ្យគន្ធបុប្ផាដោយផ្ទាល់សម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០២១, ដើម្បីធានានិរន្តរភាព, គុណភាព និង ប្រសិទ្ធភាពរបស់មន្ទីរពេទ្យ និង ធានាការ-ផ្ដល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រ ។

(៤)-*កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និង កុមារតូច រហូតដល់អាយុ ២ ឆ្នាំ* ៖ បានត្រៀមថវិកាចំនួន **៣០ ប៊ីលានរៀល** ផងដែរ ។

## ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

### ខ.១-ចំណាយមូលធនថ្នាក់ជាតិ

ត្រូវបានគ្រោងប្រមាណ **១៣ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៣,២ ប៊ីលានដុល្លារអាមេរិក**, **គឺថយចុះ ០,១%** ធៀបនឹងច្បាប់ឆ្នាំ ២០២០, មានសមាមាត្រស្មើនឹង **៤២,៨% នៃចំណាយថវិកាថ្នាក់ជាតិសរុប**, ត្រូវជា **១១,០៦%** នៃ ផសស, ដែលក្នុងនោះ ៖

(១)-**គម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** **មានកំណើន ៨,៤%** ធៀបនឹងច្បាប់ឆ្នាំ ២០២០, ហើយត្រូវជា **៥,៤២%** នៃ ផសស ដើម្បីអនុវត្តគោល-នយោបាយវិត្តារកម្មថវិកា ដោយផ្ដល់អាទិភាពទៅលើ ៖

- ការបន្ត**អន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩** មានជាអាទិ៍ ៖
  - ✓ កម្មវិធីឧបត្ថម្ភគ្រួសារក្រីក្រ (ក្រ១ និង ក្រ២) និង ជនងាយរងគ្រោះ ត្រូវបានគ្រោងទឹកប្រាក់ចំនួន៨២០ ប៊ីលានរៀល សមមូលនឹងប្រមាណ២០០ លានដុល្លារអាមេរិក,
  - ✓ កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និង ការជួយកម្មករព្យួរកិច្ចសន្យាការងារ ត្រូវបានគ្រោងទឹកប្រាក់ចំនួន ២៣៩ ប៊ីលានរៀល សមមូលនឹងប្រមាណ ៥៩ លានដុល្លារអាមេរិក,
  - ✓ គម្រោងសាច់ប្រាក់ពលកម្ម (Cash for Works) ត្រូវបានគ្រោងទឹកប្រាក់ចំនួន ៦៥០ ប៊ីលានរៀល សមមូលនឹងប្រមាណ ១៦០ លានដុល្លារអាមេរិក សម្រាប់ស្រូបយកកម្លាំងពលកម្មដែលបាត់បង់ការងារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅជនបទ មានដូចជា ការជួសជុលផ្លូវជនបទដែលរងការខូចខាតដោយជំនន់ទឹកភ្លៀងបច្ចុប្បន្ននេះ, ការកសាងប្រឡាយជើងក្អែប ស្រះទឹក អណ្តូង និង បង្គន់អនាម័យ នៅតាមសាលារៀនជាដើម,
  - ✓ មូលនិធិត្រៀមបម្រុងសម្រាប់គាំទ្រដល់សេដ្ឋកិច្ច/សហគ្រាសធុនតូច និង មធ្យម ចំនួន ១ ០៩៧ ប៊ីលានរៀល សមមូលនឹងប្រមាណ ២៧០ លានដុល្លារ;
- ការកសាង និង ជួសជុលផ្លូវចំនួន ៣៨ ខ្សែ ក្នុងទីរួមខេត្តសៀមរាប;
- ការកសាង និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់, ស្ពាន, លូ, ព្រមទាំងការជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំង ប្រព័ន្ធចម្រោះ និង បង្ហូរទឹកកខ្វក់, ប្រព័ន្ធលូ, អូរ និង ប្រឡាយរំដោះទឹកភ្លៀង;
- ការកសាង ស្តារ និង ជួសជុលប្រព័ន្ធធារាសាស្ត្រ ជាពិសេស ប្រព័ន្ធដែលរងផលប៉ះ-ពាល់ពីជំនន់ទឹកភ្លៀង;
- ការជំរុញផលិតកម្មស្បៀង និង ការលើកកម្ពស់ផលិតភាពកសិកម្ម;
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំ និង បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ;
- ការពង្រឹកសមត្ថភាពបញ្ជូន, ចែកចាយ និង ផ្គត់ផ្គង់អគ្គិសនី ។

(២)-**គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស** មានការ**ថយចុះ ៩,៧%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០, ត្រូវជា **៤,៦៣%** នៃ ផសស ដែលស្មើនឹងប្រមាណ **១៧,១% នៃចំណាយថវិការដ្ឋសរុបឆ្នាំ** ២០២១ ។

## ខ.២-ការកំណត់ពិតាននៃការខ្ចីៈសម្រាប់ឆ្នាំ ២០២១

រាជរដ្ឋាភិបាលកំណត់ **ទំហំនៃការខ្ចីប្រាក់ក្នុងកម្រិត ១ ៥០០ លាន SDR** ដើម្បីបំពេញសេចក្តីត្រូវការ ក្នុងការវិនិយោគសាធារណៈ ដើម្បីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ឆ្លើយតបនឹងបរិការណ៍នៃផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩ ក៏ដូចជាដើម្បីទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និង វែង ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទសូមគូសបញ្ជាក់ថា, ជារួម, **ទំហំនៃការខ្ចីនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌករដល់កម្ពុជានោះទេ ពោលគឺ ជាទិដ្ឋភាពបច្ចេកទេស ស្ថានភាពបំណុលសាធារណៈកម្ពុជានៅតែត្រូវបានវាយតម្លៃថាមាន "ចីរភាព" និង "ហានិភ័យកម្រិតទាប" ដដែល ដោយរាល់សូចនាករគន្លឹះៗនៃការគ្រប់គ្រងបំណុលរបស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ។**

## VI. អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក និង ឃុំ-សង្កាត់** មានឱនភាពថវិកាចំនួនប្រមាណ **១,១ ទ្រីលានរៀល** ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ហើយត្រូវបានបែងចែកលម្អិតជូនទៅថ្នាក់រដ្ឋបាលនីមួយៗ ។ ដូចគ្នានឹងថ្នាក់ជាតិដែរ, ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងឆ្នាំ ២០២១ នេះ ត្រូវបានរក្សាស្មើនឹងកម្រិតឆ្នាំ ២០២០ ។

## VII. អំពីបញ្ហាប្រឈម និង វិធានការក្នុងការអនុវត្តច្បាប់ថវិកាឆ្នាំ ២០២១

ការអនុវត្តក្របខណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំជម្នះនូវការលំបាក និង បញ្ហាប្រឈមមួយចំនួន, ទាំងផ្នែកចំណូល ទាំងផ្នែកចំណាយ ។ ចំពោះផ្នែកចំណូល, បញ្ហាប្រឈមចម្បងៗ គឺ ៖ **(ទី១)**-សម្ទុះនៃកំណើនចំណូលជារួមនៅមិនទាន់អាចឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការផ្នែកចំណាយ; **(ទី២)**-ចំណូលពន្ធដារផ្ទៃក្នុងអាចប្រឈមនឹងកំណើនយឺតដោយសារការថមថយកំណើនសេដ្ឋកិច្ចជារួម និង បញ្ហាប្រឈមមួយចំនួនទៀត ដែលមានលក្ខណៈជារចនាសម្ព័ន្ធ មានដូចជា ៖ ការវិវត្តយ៉ាងឆាប់រហ័សនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ហានិភ័យនៃការបាត់ចំណូលពន្ធដែលបណ្តាលមកពីការគេចវេះពន្ធ និង ការជៀសវាងពន្ធ ជាដើម ។ល។; **(ទី៣)**-ចំណូលពន្ធគយអាចប្រឈមនឹងការធ្លាក់ចុះច្រើនដោយសារ ៖ ភាពអាក់អន្លួល និង ភាពមិនប្រាកដប្រជានៃវំហូរពាណិជ្ជកម្ម នៅក្នុងបរិបទនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩, ការស្តារឡើងវិញនៃទីផ្សារនាំចេញរបស់កម្ពុជាត្រូវការពេលយូរដោយសារការអូសបន្លាយនៃវិបត្តិកូវីដ-១៩, ការបន្តប្រកាន់យកគោលនយោបាយគាំពារនិយម និង សង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាចសេដ្ឋកិច្ច, ការបាត់បង់ពន្ធ និង

អាករគយដោយកំណើនផលិតកម្មក្នុងស្រុកជំនួសការនាំចូល, ការបញ្ចុះអត្រាពន្ធគយក្រោមក្របខណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) និង ការលើកទឹកចិត្តពន្ធអាករដើម្បីទាក់ទាញវិនិយោគ, និង វត្តមាននៃអំពើរត់គេចបន្លំពន្ធ និង បទល្មើសឆ្លងដែនផ្សេងទៀត ។ល។; និង **(ទី៤)**-ការគ្រប់គ្រង និង ការប្រមូលចំណូលមិនមែនសារពើពន្ធដែលពាក់ព័ន្ធនឹងសមត្ថកិច្ច របស់ក្រសួង-ស្ថាប័នផ្សេងៗគ្នាជាច្រើន នៅជួបបញ្ហាប្រឈមមួយចំនួនផងដែរ ។ រីឯផ្នែកចំណាយវិញ, សម្ពាធនៃចំណាយ, ទាំងចំណាយបន្ទុកបុគ្គលិក, ទាំងចំណាយក្រៅបន្ទុកបុគ្គលិក, បន្តកើនឡើងឥតឈប់ឈរ ដោយសារ, ម្ខាង, តម្រូវការសម្រាប់ទ្រទ្រង់ដល់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេស ការអនុវត្តសកម្មភាពកែទម្រង់គ្រប់វិស័យ និង ការលើកកម្ពស់ជីវភាពប្រជាជន ព្រមទាំងការអនុវត្តគោលនយោបាយគាំពារសង្គម; និង ម្ខាងទៀត, តម្រូវការសម្រាប់រក្សាលំនឹងសង្គម-សេដ្ឋកិច្ចកម្ពុជា និង ការពារអាយុជីវិតប្រជាជនពីការរាតត្បាតនៃជំងឺកូវីដ-១៩ ព្រមទាំងសម្រាប់ស្តារ និង ជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ បានស្រាកស្រាន្ត ។

ដើម្បីជម្នះបញ្ហាប្រឈម និង ហានិភ័យនានា ទាំងក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និង ថវិកា ដូចបានគូសបញ្ជាក់ខាងលើ ឱ្យបានប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ និង ដើម្បីសម្រេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១, វិធានការដាក់លាក់នានា ត្រូវបានដាក់ចេញ ដូចមានចែងក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ ។

## VIII. អំពីបទប្បញ្ញត្តិស្តីពីពន្ធដារ

ក្នុងគោលដៅកែសម្រួល និង បំពេញបន្ថែមនូវលិខិតបទដ្ឋានគតិយុត្តនានា សំដៅធានាឱ្យនីតិវិធីប្រមូលពន្ធប្រព្រឹត្តទៅប្រកបដោយភាពស៊ីសង្វាក់ប្រទាក់ប្រឡា រលូន និង ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និង សកលលោក, វិធានការដូចខាងក្រោម ត្រូវបានស្នើដាក់ចេញ ៖

**ទី១. ធ្វើវិសោធនកម្មមាត្រា ៧២ នៃច្បាប់ស្តីពីសារពើពន្ធ ដោយធ្វើការកែសម្រួលបញ្ចូលខ្លឹមសារបន្ថែម ទាក់ទិននឹងការដាក់ឱ្យអនុវត្តយន្តការបង្វិលសងអាករលើតម្លៃបន្ថែមសម្រាប់ទេសចរ** ដើម្បីគាំទ្រគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទាញទេសចរបរទេស ។

**ទី២. ធ្វើវិសោធនកម្មមាត្រា ៤០ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដោយអនុគ្រោះលុបការបង់ពន្ធប្រថាប់ត្រា ១ ០០០ ០០០ រៀល ចំពោះការចុះបញ្ជីពន្ធដារ** ដើម្បីកែលម្អ

បរិយាកាសវិនិយោគនៅកម្ពុជាឱ្យកាន់តែមានភាពងាយស្រួល និង គាំទ្រដល់ការដាក់ឱ្យអនុវត្តការចុះបញ្ជីពន្ធដារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform) តែមួយកន្លែង និងសម្រាលបន្ទុកចំណាយលើការចុះបញ្ជី ។

## IX. និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលស្នើធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ដើម្បីគោលដៅដូចខាងក្រោម ៖

**(ទី១)**-ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ចំនួន **៣២៨ ៦០០ លានរៀល** ក្នុងនោះ សម្រាប់គាំទ្រដល់សិប្បកម្ម សហគ្រាសធុនតូច និង មធ្យម ក្នុងវិស័យកែច្នៃផលិតផលកសិកម្ម, វិស័យកសិ-ឧស្សាហកម្ម, និង វិស័យកសិកម្ម ចំនួន **២០៥ ០០០ លានរៀល** និងសម្រាប់ផ្តល់ឥណទានដល់រោងម៉ាស៊ីនកិនស្រូវ ដើម្បីប្រមូលទិញស្រូវពីប្រជាកសិករ ក្នុងរដូវប្រមូលផលធំចុងឆ្នាំ ២០២០ ចំនួន **១២៣ ៦០០ លានរៀល** ។

**(ទី២)**-ផ្តល់ជូនក្រសួងសុខាភិបាល ចំនួន **១២៣ ០០០ លានរៀល** សម្រាប់ឧបត្ថម្ភធនដល់មន្ទីរពេទ្យកាល់ម៉ែត ដើម្បីអនុវត្តគម្រោងសាងសង់អគារមេជ្ឈមណ្ឌលពហុឯកទេស ។

**(ទី៣)**-ផ្តល់ទុនដល់សាជីវកម្មធានាឥណទានកម្ពុជា ចំនួន **៨២៤ ០០០ លានរៀល** ។

**(ទី៤)**-ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ សង្កាត់ ចំនួន **១៤០ ០៦៩,២ លានរៀល** ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ។

**(ទី៥)**-សុំការយល់ព្រមអនុញ្ញាតឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែម ចំនួន **៥០០ លាន SDR** ។

## X. សេចក្តីសន្និដ្ឋាន

សរុបមក, នៅក្នុងការរៀបចំថវិកាឆ្នាំ ២០២១, ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈម និងហានិភ័យមួយចំនួនយ៉ាងណាក្តី, ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជសម្រាប់អនុវត្តអាទិភាពគោលនយោបាយសំខាន់ៗជាសារវន្ត, ស្របតាម **គោលនយោបាយវិត្តារកម្មថវិកា** ដែលត្រូវបានកំណត់នៅក្នុង **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ **ចំណាយចាំបាច់**

**ទាំងឡាយសំដៅទប់ទល់នឹងការរាតត្បាត និង កាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ និង ដោះស្រាយផលប៉ះពាល់ធ្ងន់ធ្ងរពីជំនន់ទឹកភ្លៀងដែលកើតឡើងថ្មីៗនេះ ។**

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ, **សូមសម្តេចអគ្គមហាពញាចក្រី** និង **អង្គសភាទាំងមូល** មេត្តាពិនិត្យ និង ផ្តល់ការអនុម័តលើ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១** ដោយអនុគ្រោះ ។

សូមអរគុណ!